# ជំហានទី២

ការជឿលើអំណាចដ៏អស្ចារ្យមួយ ដែលអាចស្តារជីវិតរបស់យើងឲ្យមានភាពល្អប្រសើរឡើងវិញបាន។ បន្ទាប់ពីក្រុមមនុស្សថ្មីមួយចំនួនបានឈានចូលដល់ជំហានទី២របស់**អេអេ** អ្នកខ្លះមានអារម្មណ៍ថាពួកគេហាក់បីដូចជាទើបតែឆ្លងកាត់នឹងឧបសគ្គរួចមកទេ ហើយឥឡូវកមកជួបនឹងឧបសគ្គថ្មីបន្ថែមទៀត។

ពួកគេបាននិយាយថា **អេអេ** បានធ្វើឲ្យយើងហានទទួលស្គាល់ខ្លួនឯងថាពួកយើងពិតជាអ្នកញៀនស្រា ហើយពិតជាមិនអាចគ្រប់គ្រងជីវិតរបស់ខ្លួងឯងបានពិតមែន។ **អេអេ** បានធ្វើឲ្យយើងបានយល់ពីភាពតែលតោល ដែលយើងបានមកពីការញៀនគ្រឿងស្រវឹង ហើយ**អេអេ**បានប្រាប់ទៀតថា ឥឡូវនេះមានដំណោះស្រាយតែមួយគត់ដែលអាចជួយពួកយើងចាកចេញពីការញៀនស្រានោះបាន នោះគឺជាព្រះ និងអំណាចដ៏អស្ចារ្យរបស់ទ្រង់។ ពួកយើងគេបដិសេធមិនជឿលើព្រះ ហើយខ្លះទៀតនិងមិនអាចជឿព្រះទេ ហើយក៏ខ្លះទៀតនៃពួកយើងអ្នកដែលជាអ្នកជឿព្រះអង្គ ពួកគេមិនជឿថាព្រះអង្គអាចបញ្ឈប់ការញៀនរបស់ពួកគេបានឡើយ។ តើយើងនឹងធ្វើយ៉ាងម៉េចដើម្បីអាចបញ្ឈប់ការញៀននោះបាន បើមនុស្សយើងមិនព្រមទទួលយកព្រះឲ្យទ្រង់ជួយពួកយើងផងនោះ?

អ្នកញៀនស្រាជាច្រើនក៏ដូចជាមនុស្សទូទៅជាច្រើនទៀតដែរពួកគេមានទស្សនៈ ផ្ទាល់ខ្លួនរបស់ពួកគេចំពោះជីវិតរស់នៅ និងចំពោះពិភពលោករបស់ពួកគេ គេពេញចិត្ត គេរីករាយ គេបានឈ្លក់វង្វេង រវើរវាយលើគំនិតរបស់គេដោយគេគិតថាទស្សនៈគំនិតរបស់គេ គឺវាត្រឹមត្រូវល្អឥតខ្ចោះហើយគ្មានរណាអាចប្រៀបបានឡើយ ដូចនេះហើយពួកគេមិនចង់ឲ្យនរណាម្នាក់មកកែប្រែគំនិតគេនោះទេ ឬក៏បញ្ញាគេឡើយ។ ដោយសារតែគេគិតដូច្នេះហើយ ទើបគេព្យាយាមរកអ្វីៗដែលគេត្រូវការ មកបំពេញចិត្តគេ ដើម្បីកំសាន្តចិត្តរបស់គេ ហេតុនេះហើយទើបគេជំទាស់ ឬមិនទទួលយកបំណងល្អពីអ្នកដទៃ។

ចំពោះអ្នកញៀនស្រាគេតែងតែគិត និងនាំយកនូវអ្វីផ្សេងៗដើម្បីយកមកបំពេញចិត្ត លួងចិត្តរបស់ខ្លួនគេ។ នៅពេលដែល**អេអេ** បានលើកអំពីគំនិតមួយដោយយកព្រះ និងអំណាចចេស្តារបស់ទ្រង់មកធ្វើជាដំណោះស្រាយ នោះវាហាក់បីដូចជាការគំរាមគំហែងមួយចំពោះពួកគេ។ ក្រុមអ្នកចូលរួម**អេអេ** ថ្មីពួកគេបានប្រឆាំងជំទាស់អំពីគំនិតនេះជាមួយទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ ចំពោះការដែលឲ្យគេសារភាពថាគេពិតជាអ្នកញៀនស្រា ហើយពិតជាមិនអាចគ្រប់គ្រងជីវិតរបស់ខ្លួនគេបានមែន។ ពួកគេបានឆ្លងកាត់ជំហានទីមួយ ដែលជំហានដ៏លំបាក។ ជំហានទី១គឺឲ្យពួកគេបានសារភាព និងទទួលស្គាល់ខ្លួនថាគេពិតជាអ្នកញៀនគ្រឿងស្រវឹងមែន។ ឥឡូវនៅក្នុងជំហានទី២នេះគាត់នឹងជួបឧបសគ្គផ្សេងទៀត ដែលនឹងជាការលំបាកបន្ថែមទៀត។

សមាជិកថ្មីរបស់អេអេអាចមិនពេញចិត្តចំពោះគំនិតដែលយើងបានយកព្រះ និងអំណាចដ៏ខ្ពង់ខ្ពស់របស់ទ្រង់មកធ្វើជាផ្នែកមួយនៃផែនការរបស់**អេអេ**។ ចំពោះអ្នកមកចូលរួមថ្មីរបស់**អេអេ** ត្រូវយល់ថាអ្នកចូលរួម**អេអេ** ពីមុនក៏ដូចគ្នា ពីមុនគេបដិសេធមិនទទួលយកគំនិតបែបនេះ តែក្រោយមកពួកគេក៏ទទួលយក បន្ទាប់មកពួកគេក៏បានមានការផ្លាស់ប្តូរកែប្រែលដ៏ល្អដោយពួកគេមានជីវិតរស់នៅប្រសើរឡើង រឿងនេះវាក៏ដូចគ្នាទៅនឹងសមាជិក**អេអេ**ថ្មីនេះដែរ។

អ្នកផ្តល់ឱវាទរបស់**អេអេ**ចំពោះអ្នកចូលរួមថ្មីបានរំលឹកពួកគេថា៖

**១. អេអេ**មិនបានបង្ខំ ឬទាមទារអោយពួកគេត្រូវតែជឿលើ**អេអេ**នោះទេ។ ប៉ុន្តែចំពោះជំហានទាំង១២ នោះវាគ្រាន់តែជាការស្នើរសម្រាប់អ្នកដែលញៀនស្រា បើពួកគេចង់ផ្តាច់ការញៀនស្រានោះ។

២. ដើម្បីផ្តាច់ពីការញៀនស្រា និងឲ្យមានភាពជ្រះស្រឡះពីស្រា គឺអ្នកមិនចាំបាច់ត្រូវធ្វើតាម ជំហានទី២ទាំងអស់នោះទេ តែអ្នកត្រូវតែទទួលយកមួយចំណែកខ្លះរបស់វា នោះគឺបានហើយ។

៣. ព្យាយាមបើកចំហចិត្ត ចំពោះគំនិតនេះ ហើយបញ្ឈប់ការប្រឆាំងជំទាស់ ត្រូវបើកចិត្តឲ្យទូលាយ ហើយទទួលយកវា។

នៅថ្ងៃដំបូងរបស់ខ្ញុំក្នុងកម្មវិធី**អេអេ** ខ្ញុំក៏បានជំទាស់ចំពោះគំនិតយោលបល់ដែលបានលើកយកព្រះ និងអំណាចរបស់ទ្រង់មកពាក់ព័ន្ធនឹងការយល់ឃើញរបស់ខ្ញុំដែរ ប៉ុន្តែខ្ញុំបានចាំថាគ្រូផ្នែកវិទ្យាសាស្ត្ររបស់ខ្ញុំបានប្រាប់ខ្ញុំអំពីគោលការណ៍នៃការវិវត្តរបស់វិទ្យាសាស្ត្រថា គឺត្រូវសិក្សាស្រាវជ្រាវម្តងហើយម្តងទៀតជាមួយនឹងការបើកចិត្តឲ្យទូលាយ។

តាមអ្វីដែលខ្ញុំបានគិត**អេអេ**មិនមានគំនិតណាមួយតាមបែបវិទ្យាសាស្ត្រទាល់តែសោះ។ ប៉ុន្តែផ្ទុយមកវិញអ្នកដែលបានបិទគំនិតក្នុងការទទួលយកគំនិតនោះ គឺជាខ្ញុំទៅវិញទេ។

សូមមើលលទ្ធផលរបស់**អេអេ** គឺវាមិនមែនមនុស្សទាំងអស់ទេ ប៉ុន្តែមនុស្សជាច្រើនអាចផ្តាច់ការញៀនស្រា។ ពួកគេត្រូវបានផ្តល់ជូននូវឱកាសក្នុងការរស់នៅជាមួយជីវិតថ្មីរបស់ពួកគេ។ ចាប់ពីពេលដែលខ្ញុំបានឈប់ប្រឆាំងជំទាស់តវ៉ានឹងគំនិតនោះមក ខ្ញុំបើកចិត្តចំពោះអំណាចមួយពេលនោះបញ្ហា និងឧបសគ្គក៏បានថយចុះ។

ក្រោយពីនោះមិនយូរប៉ុន្មានខ្ញុំពិតជាមិនមានបញ្ហាអ្វីជាមួយនិងការបើកចិត្តចំពោះព្រះ ឬជាមួយនឹងអំណាចដ៏អស្ចារ្យរបស់ព្រះអង្គដែលបានស្តារជីវិតខ្ញុំឡើងវិញ។ មនុស្សមួយចំនួនលំបាកនឹងជឿលើព្រះអង្គ ដូចនេះដោយពឹងផ្អែកទៅលើ**អេអេ** តាមរយៈការប្រកបគ្នាដោយមានការលើកទឹកចិត្តគ្នា ការពិភាក្សាគ្នា ការបញ្ចេញមតិយោបល់រួមចិត្តគំនិតគ្នា ការចែករំលែកបទពិសោធន៍នានាដែល**អេអេ**ធ្លាប់ឆ្លងកាត់ នោះវាគឺជាថាមពលអំណាចដ៏អស្ចារ្យដើម្បីជួយស្តាពួកគេបាន។

ក្រុមមួយចំនួនធំនៃ**អេអេ** គេបានដោះស្រាយនូវបញ្ហាញៀនស្រារបស់ពួកគេ នោះវាជាអំណាចដ៏អស្ចារ្យមួយដែលវាធំជាង ហើយខ្ពង់ខ្ពស់ជាងអំណាចរបស់មនុស្សម្នាក់។ មានមនុស្សជាច្រើនដែលធ្លាប់ចូលរួមជាមួយក្រុម**អេអេ** ពួកគេបានពឹងផ្អែកទៅលើអំណាចដ៏ខ្ពស់របស់គេរហូតដល់គេបានធូស្រាល ពីភាពស្រវឹងដ៏ងប់ងល់របស់ពួកគេ។ នៅពេលដែលពួកគេបានធូស្រាលហើយ វាជារឿងមួយដ៏ងាយស្រួលក្នុងការព្រមទទួលជឿលើព្រះអង្គ។

អ្នកខ្លះធ្លាប់ជឿព្រះហើយក៏ឈប់ជឿទៅវិញ ហើយអ្នកខ្លះទៀតគេក៏មិនដែលខ្វល់ពីរឿងនេះដែរ។ អ្នកខ្លះទៀតគេបានកត់សំគាល់ថាគេអាចពឹងផ្អែកទៅលើខ្លួនរបស់គេបាន ដោយមិនបាច់មានជំនឿចំពោះព្រះនោះទេ។ ដូចនេះហើយទើបគេបានកាត់ផ្តាច់ខ្លួនរបស់គេចេញពីព្រះ ហើយក៏នៅមានអ្នកខ្លះទៀតគេបានចាកចេញពីជំនឿក៏ដោយសារតែព្រះអង្គមិនបានជួយ និងបំពេញឲ្យគេនូវចំណុចខ្វះខាតដែលគេត្រូវការ។ ចូរមើលទៅ**អេអេ** យោងទៅតាមសេចក្តីជំនឿរបស់ពួកគេមាន តើពួកគេបានសំរេចយ៉ាងណាទៅហើយ។ ជួនកាល **អេអេ**មានភាព លំបាកច្រើនចំពោះអ្នកដែលបាត់បង់ និងអ្នកដែលបដិសេធនូវក្តីជំនឿរបស់ពួកគេនោះវាលំបាកជាងអ្នកដែលមិនធ្លាប់ជឿទៅទៀត។ ពីព្រោះគេធ្លាប់ព្យាយាមធ្វើវាប៉ុន្តែពួកគេមិនបានទទួលលទ្ធផលឡើយ។ ឧបសគ្គទាំងប៉ុន្មានខាងលើ វាធ្វើឲ្យកាន់តែលំបាកសម្រាប់អ្នកដែលចង់ទទួលយកជំហានទី២នេះ វាមានន័យថាវាលំបាកជាងអ្នកដែលមិនធ្លាប់ជឿលើព្រះចេស្តារបស់ព្រះ។

មនុស្សភាគច្រើនក្នុង**អេអេ** អាចប្រាប់យើងថាហេតុផលដែលធ្វើឲ្យពួកយើងឃ្លាតឆ្ងាយពីជំនឿ គឺដោយសារតែភាពវក់វី និងភាពជាយុវវ័យ ហើយក៏គួបផ្សំជាមួយនឹងជំនឿមានភាពលំបាកផងដែរ។ ការរស់នៅដែលប្រកបទៅដោយភាពត្រឹមត្រូវ និងទង្វើដែលយើងប្រព្រឹត្តទៅលើអ្នកដទៃ វាគួរតែគ្រប់គ្រាន់ចំពោះអ្វីដែលយើងត្រូវការសំរាប់ជីវិតរស់នៅ។ វានឹងធ្វើឲ្យយើងមានភាពជោគជ័យក្នុងជីវិតរបស់ពួកយើងម្នាក់ៗ ពួកយើងគួរតែស្វែងរកជំនឿដែលយើងបានបាត់បង់។ មានមនុស្សមួយប្រភេទទៀតដែលគេគិតថាពួកគេឆ្លាតជាងអ្នកដទៃទាំងអស់ ពីព្រោះពួកចូលចិត្ត

តាំងខ្លួន និងលើកខ្លួនឯងថាខ្ពស់ជាងគេទាំងអស់នៅក្នុងទីសាធារណៈ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយក៏ដូចជានៅក្នុងកិច្ចការសង្គមនានាផងដែរ។ ពួកយើងចូលចិត្តយកកំរិតនៃការសិក្សារបស់យើងមកធ្វើឲ្យវាល្អប្រសើរលើសគេ។ ដូចនេះហើយទើបយើងគិតថាយើងគួរតែមានតួនាទី ឬមុខងារខ្ពស់ជាងអ្នកដទៃទៀត។ ពួកយើងជាអ្នកដែលជឿលើវិទ្យាសាស្ត្រ ព្រោះវិទ្យាសាស្ត្របានប្រាប់ពួកយើងថាគ្មានអ្វីដែលមនុស្សយើងធ្វើមិនបានឡើយ ហេតុនេះហើយទើបយើងគិតថាចំណេះដឹងដែលយើងមានវាប្រៀបដូចអំណាចដ៏ខ្លាំងមួយ។ ដូចនេះហើយអាស្រ័យលើចំណេះ និងជំនាញដែលយើងមាននោះដែល ធ្វើឲ្យយើងគិតថាវាជាអំណាចមួយដ៏អស្ចារ្យ លើសគេទើបយើងគិតថាក្នុងសង្គមនេះអ្វីទាំងអស់វាគួរតែយើងអាចធ្វើបាន ព្រោះវាជាសិទ្ធិរបស់យើង។ ពួកយើងធ្លាប់ជាអ្នកឈ្នះ ដោយអាស្រ័យលើបញ្ញារបស់យើង ប៉ុន្តែមិនយូមិនឆាប់យើងនឹងក្លាយជាអ្នកចាញ់ បើសិនជាស្រាវាចូលមកកាន់កាប់ជីវិតរបស់ពួកយើង។ យើងគួរតែគិតវាឡើងវិញបើសិនជាយើងមិនចង់ស្លាប់។

អ្នកចូលរួមអេអេដំបូងគេភាគច្រើនគេធ្លាប់គិតអំពីបញ្ហានេះ អ្នកធ្លាប់ចូលរួម**អេអេ**ជំនាន់មុនគេប្រាប់ឲ្យយើងដឹងថា បញ្ញា និងការបន្ទាបខ្លួនទាំងពីរនេះ ដែលយើងគួរតែមានវាព្រមគ្នា ប៉ុន្តែការបន្ទាបខ្លួនគួរតែមកមុន។ នៅពេលដែលយើងបានរៀនបន្ទាបខ្លួនយើងហើយ នោះយើងចាប់ផ្តើមមានជំនឿខ្លះៗ។

មនុស្សមួយប្រភេទផ្សេងទៀតក្នុងអេអេបានរកឃើញនូវអ្នកដែលកាន់សាសនា ជាមនុស្សលាក់ពុតហើយគេយល់ថាខ្លួនរបស់គេត្រូវរហូត ហើយគេស្អប់ពួកផ្សេងទៀតប៉ុន្តែគេស្រលាញ់បក្សពួកខ្លួនឯង។

នៅក្នុងព្រះគម្ពី និងសៀវភៅអត្ថបទខ្លះមានការអធិប្បាយខុសៗគ្នា ខ្លះគេនិយាយបែបនេះខ្លះទៅគេនិយាយបែបផ្សេងទៅវិញ។ ពួកគេបានឃើញថា អ្នកកាន់សាសនាបានប្រាប់ពីជំបូន្មានទៅអ្នកផ្សេងទៀតប៉ុន្តែពួកគេមិនបានធ្វើតាមទេ ដូចនេះហើយទើបអ្នកដែលទទួលបន្ទុកផ្នែកសាសនា ឬអ្នកដែលកាន់សាសនាទាំងនោះកំពុងតែឈ្លោះគ្នាកាប់សំលាប់គ្នាទៅវិញទៅមក។ ពួកគេពិតជាមានភាពធុញទ្រាន់ចំពោះសាសនា និងអ្នកកាន់សាសនាទាំងនោះ។ នេះគឺជាគំនិតអវិជ្ជមានមួយដែលយើងបានមើលស្រាល ឬបន្ទាបលើសាសនាផ្សេងៗ ហើយបែរជាមកលើកសរសើរថាខ្លួនឯងល្អអស្ចារ្យទៅវិញ។ នៅពេលដែលយើងរវល់តែស្អប់ រុកគួនអ្នកដទៃនោះវាធ្វើឲ្យយើងមិនបានគិតអំពីបាប និងភាពខ្សោយរបស់ខ្លួនយើងឡើយ ដោយរវល់តែគិតថាខ្លួនឯងត្រូវ ហើយបន្ទោសទៅអ្នកដទៃ។ វាគឺពិតជារឿងមួយដ៏គួឲ្យយើងអាមាសជាទីបំផុតសម្រាប់ខ្លួនយើង ហើយយើងក៏មិនអាចកែប្រែខ្លួនយើងបានឡើយ។ យើងបានបង្កើតរូបភាពក្លែងក្លាយមួយដែលមើលទៅគួរឲ្យគោរព ដើម្បីបញ្ចៀសខ្លួនយើងឲ្យចេញពីជំនឿផ្សេងៗ។ បន្ទាប់ពីការចូលរួមជាមួយ**អេអេ** ពួកយើងបានរៀននូវមេរៀនជាច្រើន ហើយពួកយើងក៏មានភាពល្អប្រសើរជាងមុន។ ពេទ្យផ្នែកចិត្តវិទ្យាជាច្រើនសង្កេតឃើញថាភាពមានះ គឺជាចរិកលក្ខណៈរបស់អ្នកញៀនស្រាជាច្រើនដែលតែងតែមាន ដូច្នេះវាមិនមែនជារឿងចម្លែកនោះទេដែលអ្នកញៀនស្រា ពួកគេបានកំពុងប្រឆាំងចំពោះព្រះ និងអ្នកផ្សេងទៀត។ ពេលខ្លះព្រះមិនបានផ្តល់អ្វីល្អៗឲ្យយើងសំរាប់ជីវិតនោះទេ ដូចជាលោកសាន់តាក្លោសជាដើម។ ពួកយើងបានប្រែក្លាយជាខឹង ក្លាយទៅជាកូនដែលរឹងទទឹង។ ជាញឹកញាម់នៅពេលដែលពួកយើងជួបប្រទះទុក្ខលំបាកធំៗ ឬក៏វិបត្តិនៃជីវិត ហើយបាត់បង់វត្ថុជាទីស្រឡាញ់របស់ពួកយើង នោះពួកយើងអស់ជំនឿលើព្រះ ហើយយើងមានអារម្មណ៍ថាទ្រង់បានចាកចេញពីយើង ទ្រង់បានភ្លេចពួកយើង។ ឧទាហរណ៍ស្ត្រីម្នាក់ចង់រៀបការជាមួយយើងប៉ុន្តែនាងបានផ្លាស់ប្តូរគំនិត ហើយយើងក៏បានអធិស្ឋានសូមទៅព្រះអង្គឲ្យនាងផ្លាស់ប្តូរគំនិត ប៉ុន្តែនាងមិនបានផ្លាស់ប្តូរគំនិតនោះទេ។ ពួកយើងបានអធិស្ឋាន សូមឲ្យកូនៗពួកយើងមានសុខភាពល្អ ជៀសផុតពីជំងឺទាំងអស់របស់យើង។ យើងបានអធិស្ឋានសូមទ្រង់នៅឯកន្លែងធ្វើការឲ្យពួកយើងមានតួនាទីល្អប៉ុន្តែវាមិនបានកើតឡើងទាល់តែសោះ។

ដូចនេះយើងបានបាត់បង់មនុស្សជាទីស្រលាញ់ម្នាក់ ដែលយើងអាចពឹងផ្អែកបាននៅក្នុងជីវិតរបស់យើង។ ដោយសារតែគំនុំរបស់ពួកយើង វាបានធ្វើអោយពួកយើងក្លាយទៅជាមនុស្សស្រវឹងរឹងចចេះ ហើយយើង អធិស្ឋានសូមទ្រង់ឲ្យពួកយើងរួចផុតពីទុក្ខសោកនោះតែទ្រង់មិនបានឆ្លើយតបនោះទេ។ នេះគឺជាការឈឺចាប់ដ៏ខ្លាំងបំផុតលើសពី

អ្វីដែលយើងធ្លាប់ជួប។ វាបានធ្វើឲ្យយើងរឹតតែកាត់ផ្ដាច់ទ្រង់ចេញសែនឆ្ងាយពីជីវិតរបស់យើងទៅទៀត ហើយក៏ឈប់ជឿលើព្រះអង្គតែម្ដង។ នៅពេលដែលពួកយើងបានចូលរួម ហើយបានស្គាល់**អេអេ** ពួកយើងបានឃើញច្បាស់ថាហេតុផលទាំងអស់នោះ គឺខុសចំពោះភាពរឹងចចេះរបស់ពួកយើង។ ពួកយើងមិនដែរស្នើរសុំព្រះ នូវអ្វីដែរព្រះអង្គអាចឲ្យយើងនោះទេ ពួកយើងបែរជាស្នើរសុំទ្រង់នូវអ្វីដែលយើងត្រូវការតាមចិត្តខ្លួនឯង។ ពួកយើងបានដឹងហើយថាគ្មាននរណាម្នាក់អាចជឿទ្រង់ ហើយបំពានទ្រង់នៅពេលតែមួយនោះទេ សេចក្ដីជំនឿគឺជាការទុកចិត្ត គឺជាសេចក្ដីសង្ឃឹម ហើយវាមិនមែនជាការជំទាស់នោះទេ។ បើយើងមើលទៅក្នុង**អេអេ** ផលផ្លែនៃសេចក្ដីជំនឿដែលពួកគេបានទទួលដោយសារតែពួកគេបានធ្វើការទុកចិត្តនៅលើព្រះ នោះទ្រង់បានដកពួកគេចេញ ពីគ្រោះមហន្តរាយឲ្យរួចផុតពីសេចក្ដីស្លាប់។ ដច្នេះពួកយើងឃើញថាពួកគេបានប្រឈមមុខទៅនឹងបញ្ហាផ្សេងៗដូចជា ការឈឺចាប់ដ៏ខ្លាំង និងការកាត់ទោសជាដើម។

នៅពេលដែលពួកយើងឃើញការប្រែប្រួលទាំងនោះ យើងក៏ដឹងថាការជឿលើកព្រះ ឬជឿលើ អំណាចចេស្ដារបស់ទ្រង់ វាមិនមែនជាតម្លៃដ៏ខ្ពស់ហួសហេតុដែលយើងត្រូវបំណាយនោះទេ។ ប្រភេទមួយផ្សេងទៀតគឺ អ្នកផឹកដែលកាន់សាសនាគាត់បាននិយាយថាគាត់ជឿព្រះ គាត់ទៅព្រះវិហារទៀងទាត់ ទៅវត្តទៀងទាត់ ហើយគាត់ដើរតាមកន្លងនៃសាសនា។ ‘គាត់ពិតជានៅតែជឿលើព្រះ ប៉ុន្តែគាត់សង្ស័យថាព្រះមិនបានទុកចិត្តលើគាត់ទៅវិញ”។ គាត់បានសន្យានឹងទ្រង់ថាគាត់មិនផឹកស្រាទៀតទេ ប៉ុន្តែថ្ងៃបន្ទាប់ប៉ុន្តែគាត់នៅតែផឹកទៀត គាត់មិនត្រឹមតែផឹកតែម្ដងនោះទេគាត់ថែមទាំងផឹកច្រើនជាងមុនទ្វេរដងទៅទៀត គាត់ព្យាយាមយ៉ាងលំបាកក្នុងការប្រឆាំង នឹងការញៀនស្រាដោយខ្លួនគាត់ផ្ទាល់ ដោយការទូលអង្វរសុំជំនួយពីព្រះ ប៉ុន្តែជំនួយនោះមិនបានកើតឡើងនោះទេ។ តើអ្វីជាបញ្ហា? ប្រភេទនេះអ្នកដែលនិយាយថាគាត់មានជំនឿប៉ុន្តែជីវិតរបស់គាត់ពោរពេញដោយភាពអាប់អួរ គឺវាក៏ដូចនឹងមនុស្សជាច្រើនរបស់**អេអេ** ដែលពេលដំបូងពួកយើងបានគិតថាពួកយើងមានជំនឿ ពួកយើងជាមនុស្សបន្ទាបខ្លួន ប៉ុន្តែជំនឿរបស់ពួកយើងនោះគឺវាមិនមានគុណភាពអ្វីសោះ។ និយាយពីឧបសគ្គ និងបញ្ហាដ៏ធំបំផុតដែលមិនអាចឲ្យទ្រង់ធ្វើការក្នុងជីវិតរបស់យើងនោះដោយសារតែសេចក្ដីជំនឿរបស់យើងមិនច្បាស់លាស់ មិនចេញពីដួងចិត្ត។ យើងថាខ្លួនយើងដើរតាមទ្រង់ តែការពិតបែរជាយើងមិនមានជំនឿលើទ្រង់ទៅវិញ ដោយដើរតាមគំនិត កំលាំង និងប្រាជ្ញាខ្លួនឯង។

យើងមិនធ្លាប់បានពិនិត្យមើលឲ្យបានច្បាស់លាស់ពីជីវិតរបស់ពួកយើងនោះទេ យើងមិនដែលធ្វើការលប់លាងទោសចំពោះអ្វីដែលយើងបានធ្វើទៅលើអ្នកដទៃនោះទេ យើងមិនដែលជួយអ្នកដទៃដោយមិនរំពឹងថាគេនឹងជួយយើងវិញនោះទេ។ ពួកយើងតែងតែអធិស្ឋានសុំទ្រង់ឲ្យទ្រង់សម្រេចតាមបំណងរបស់ពួកយើង។ ដូចនេះពួកយើងបានស្ថិតនៅជាមួយការបន្លំខ្លួនយើង ដោយគិតថាអ្វីដែលយើងមាននោះ គឺជាជំនឿពិត។ ដូចនេះហើយដែលធ្វើឲ្យយើងឃ្លាតឆ្ងាយពីព្រះអង្គកាន់តែឆ្ងាយទៅៗ យើងមិនអាចទទួលយកជំនួយរបស់ព្រះនៅក្នុងការស្តារជីវិតយើងចេញពីភាពឆ្កួតវង្វេងនោះបានទេ។ អ្នកញៀនស្រាគេមិនបានដឹងថាប្រព័ន្ធគំនិតរបស់គេមានភាពមិនប្រក្រតីនោះទេ តែបើគេបានដឹងថាខ្លួនគេមានភាពមិនប្រក្រតី នោះគេមិនអាចប្រឈមមុខឬក៏ព្រមទទួលយកវាបានទេ។ អ្នកញៀនស្រាជាច្រើន គេរាប់ខ្លួនគេថាជាអ្នកផឹកដ៏ខ្លាំង ប៉ុន្តែភាគច្រើនគេមិនបានដឹងថាខ្លួនរបស់គេមានបញ្ហាផ្លូវចិត្តឬក៏មានបញ្ហារខួរក្បាលនោះទេ។ ភាពប្រក្រតី គឺមានន័យថាមនុស្សដែលមានផ្លូវចិត្តល្អ។ គ្មានអ្នកញៀនស្រាណាម្នាក់ដែលអាចវាយតម្លៃទៅលើគំនិតរបស់ខ្លួនដែលប្រកបទៅដោយទស្សនៈប្រក្រតីនោះទេ។ នៅក្នុង គោលគំនិតរបស់ខ្លួនគេផ្ទាល់ គេមើលមិនឃើញថា មិនមានអ្វីដែលខុសឆ្គងនោះទេ។

ជំហានទី២៖ បានស្នើឲ្យយើងបេះបន្ទាបខ្លួន និងការបើកចំហរដួងចិត្តឲ្យទូលាយដែលអាចដឹកនាំយើងឲ្យមានជំនឿយ៉ាងមុតមាំបាន។ ប្រសិនបើអ្នកចង់បានភស្តុតាងជាក់ស្តែងនោះចូរក្រលេកមើលទៅការជួបគ្នារបស់ក្រុម **អេអេ**។